**នាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម**

www.vokk.net ● vokk2001@gmail.com ● (408) 550-5060

…………..☸…………..

# សេចក្តីប្រកាសព័ត៌មាន

ស្តីពី

## ការបង្កើតទំព័រ FACEBOOK ថ្មី នៃ សំឡេងកម្ពុជាក្រោម (VOKK)

សួស្តីប្រិយមិត្តជាទីមេត្រី!

នៅពេលថ្មីៗនេះ ទំព័រ Facebook Page របស់ កម្មវិធីផ្សាយ សំឡេងកម្ពុជាក្រោម ដែលមានឈ្មោះជាភាសាអង់គ្លេសថា Voice of Kampuchea Krom – VOKK បានត្រូវក្រុម Hacker ចូលគ្រប់គ្រង និងលុបចោលទាំងស្រុងហើយ ។ យើងខ្ញុំបានទាក់ទងក្រុមហ៊ុន Meta ដើម្បីជួយយកមកវិញដែរ តែមិនបានទទួលលទ្ធផលឡើយ ។ ទីបំផុត យើងខ្ញុំបានសម្រេចជាឯកច្ឆន្ទបង្កើតជាទំព័រ (Page) ថ្មីមួយទៀត ដែលមានឈ្មោះដូចដើមដដែលជាភាសាអង់គ្លេសថា Voice of Kampuchea Krom – VOKK និងមានអាសយដ្ឋានថា www.facebook.com/voiceofkampucheakrom ។

អាស្រ័យហេតុនេះ សូមប្រិយមិត្តទាំងអស់ដែលនិយមគាំទ្រ និងយកចិត្តទុកដាក់តាមដានព័ត៌មានតាមរយៈទំព័រ Facebook នៃ **សំឡេងកម្ពុជាក្រោម** (VOKK) នាពេលកន្លងមក ស្តីពីព្រឹត្តិការណ៍ផ្សេងៗ ដែលកើតឡើងនៅដែនដីកម្ពុជាក្រោម និងអំពីសកម្មភាពតស៊ូមតិដោយសន្តិវិធី និងអហិង្សានៅលើឆាកអន្តរជាតិរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) នោះ សូមមេត្តាជួយចុច **Like, Follow** និង **Share** នូវទំព័រថ្មីនេះ ដើម្បីបានទទួលព័ត៌មានថ្មីៗពីកម្មវិធីផ្សាយរបស់យើងខ្ញុំ ។

**សំឡេងកម្ពុជាក្រោម (VOKK)** ជាកម្មវិធីផ្សាយវិទ្យុ បង្កើតឡើងដោយ **សហព័ន្ធខ្មែរកម្ពុជាក្រោម** នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០០១ (២២ ឆ្នាំ) នៅសហរដ្ឋអាមេរិក ក្នុងគោលបំណងផ្សព្វផ្សាយនូវដំណឹងផ្សេងៗពីមាតុភូមិកម្ពុជាក្រោម និងអំពីសកម្មភាពតស៊ូមតិដោយសន្តិវិធី និងអហិង្សានៅលើឆាកអន្តរជាតិរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ដើម្បីនាំមកនូវ **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ជូនប្រជាជាតិជនជាតិដើមខ្មែរក្រោមរាប់លាននាក់នៅដែនដីកម្ពុជាក្រោម ដែលកំពុងតែរស់នៅក្រោមអាណានិគមវៀតណាមសព្វថ្ងៃ ។

ក្រៅពីផ្សាយតាមរយៈទំព័រ Facebook Page កម្មវិធីផ្សាយ សំឡេងកម្ពុជាក្រោម (VOKK) ក៏ធ្វើការផ្សព្វផ្សាយតាមរយៈមធ្យោបាយមួយចំនួន ដូចជា គេហទំព័រដែលមានអាសយដ្ឋាន www.vokk.net និងតាម

រយៈយូធូប ដែលមានអាសយដ្ឋាន www.youtube.com/@VoiceofKampucheaKrom ។ កម្មវិធីផ្សាយទាំងនេះ រួមមានដូចជា អត្ថបទ រូបថត វីដេអូ និងសំឡេង ជាដើម ។

បច្ចុប្បន្ន **សំឡេងកម្ពុជាក្រោម** (VOKK) ជាផ្នែកមួយ នៃកម្មវិធីផ្សាយបិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័ន **នាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម** ក្នុងចំណោមកម្មវិធីផ្សាយជាច្រើនផ្នែកផ្សេងទៀត រួមមាន **ទូរទស្សន៍អនឡាញ** តាមបណ្ដាញសង្គម Facebook និង Youtube, **អត្ថបទ**គ្រប់ប្រភេទ, បោះពុម្ពជា**សៀវភៅ**, **ព្រឹត្តិបត្រ កម្ពុជាក្រោម** និង **កាសែត ព្រៃនគរ** និងបានផលិតជា**បទចម្រៀងជាតិនិយម**រាប់រយបទ ហើយផ្ទុកនៅលើគេហទំព័រ ដើម្បីសាធារណជនគ្រប់មជ្ឈដ្ឋានបានសិក្សាស្រាវជ្រាវតាមតម្រូវការជាក់ស្ដែង ។

ទោះបីក្រុមការងាររបស់ នាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម មានការខិតខំប្រឹងប្រែងធ្វើការយ៉ាងនេះក្ដី តែសមិទ្ធផលទាំងនេះ នៅតែមិនទាន់បំពេញឲ្យបានសព្វគ្រប់ជ្រុងជ្រោយ សម្រាប់បម្រើផ្នែកបញ្ញាស្មារតីដល់សាធារណជនទូទាំងពិភពលោកនៅឡើយ ។ យើងខ្ញុំនឹងខិតខំប្រឹងប្រែងបន្ថែម និងបន្តដំណើរទៅមុខទៀត ដើម្បីធ្វើឲ្យកម្មវិធីផ្សាយរបស់យើងក្លាយជា «មជ្ឈមណ្ឌលព័ត៌មានកម្ពុជាក្រោម» ដ៏មានប្រសិទ្ធភាពមួយ ផ្សព្វផ្សាយនូវដំណឹងពិត និងទាន់ហេតុការណ៍ គួរជាទីទុកចិត្តពីប្រិយមិត្តគ្រប់ទិសទី និងធ្វើជាចន្លុះសម្រាប់ឆ្លុះបំភ្លឺដល់ពលរដ្ឋខ្មែរក្រោមរាប់លាននាក់នៅដែនដីកម្ពុជាក្រោម ដែលកំពុងតែរស់នៅក្នុងគុកងងឹតឥតជញ្ជាំងនៃរបបអាណានិគមវៀតណាម ឲ្យបានទទួលនូវពន្លឺបញ្ញាពុទ្ធិ ហើយចេះប្រើនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងការ **«សម្រេចវាសនាខ្លួនដោយខ្លួនឯង»** នៅលើមាតុភូមិដូនតារបស់ខ្លួន ។

ដោយសារមើលឃើញការផ្សាយរបស់ សំឡេងកម្ពុជាក្រោម (VOKK) មានឥទ្ធិពលគ្របដណ្ដប់លើដែនដីកម្ពុជាក្រោម និងនាំមកនូវការផ្លាស់ប្ដូរផ្នត់គំនិតរបស់ពលរដ្ឋខ្មែរក្រោមនាពេលបច្ចុប្បន្ន និងអនាគត គេបានរកវិធីគ្រប់យ៉ាងដើម្បីរារាំងនូវការផ្សាយរបស់យើង ហើយទីបំផុត ក្រុម Hacker បានចូលលុបចោលទាំងស្រុង នូវទំព័រ Facebook សំឡេងកម្ពុជាក្រោម (VOKK) របស់យើង ។ ទោះយ៉ាងនេះក្ដី ក្រុមការផ្សាយរបស់យើងបានបង្កើតជាទំព័រថ្មីមួយទៀត ដែលមានអាសយដ្ឋានខាងលើ ដើម្បីបន្តការផ្សព្វផ្សាយព័ត៌មានតទៅមុខទៀត ដោយមិនមានអំណាចអ្វីមករារាំងបានឡើយ ៕

ទីក្រុង San Jose រដ្ឋ California សហរដ្ឋអាមេរិក

ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០២៣

ភិក្ខុ **សឺង យ៉ឺង រតនា** (សុវណ្ណបញ្ញោ)

**ប្រធាននាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម**